អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១៤ ខែតុលា ឆ្នាំ ២០១៤

# សេចក្តីប្រកាសព័ត៌មាន
# សវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២ ប្រឆាំងនឹង នួន ជា និងខៀវ សំផននឹងចាប់ផ្តើមនៅថ្ងៃទី១៧ ខែតុលា ឆ្នាំ ២០១៤

អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) នឹងចាប់ផ្តើមបើកសវនាការលើអង្គសេចក្តី ក្នុងសំណុំរឿង ០០២/០២ ប្រឆាំងនឹង នួន ជា និងខៀវ សំផន **នៅថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០១៤ វេលាម៉ោង៩ព្រឹក** នៅក្នុងសាលសវនាការធំរបស់ អ.វ.ត.ក។ សហព្រះរាជអាជ្ញានឹងត្រូវអនុញ្ញាតឲ្យធ្វើសេចក្តីសន្និដ្ឋានបើកលើបទចោទប្រកាន់ចំពោះជនជាប់ចោទដោយសង្ខេប ហើយជនជាប់ចោទ និង/ឬមេធាវីការពារក្តីនឹងត្រូវផ្តល់ឱកាសក្នុងការធ្វើសេចក្តីសន្និដ្ឋានតបដោយសង្ខេបផងដែរ មុននឹងសាក្សីទី១ ត្រូវបានកោះហៅដើម្បីផ្តល់សក្ខីកម្មនៅថ្ងៃច័ន្ទ ទី២០ ខែតុលា ឆ្នាំ ២០១៤។ អង្គហេតុដែលនឹងត្រូវស្តាប់នៅក្នុងពេលសវនាការវគ្គទី១ គឺទាក់ទងនឹងសហករណ៍ត្រាំកក់ ដោយរាប់បញ្ចូលទាំងការប្រព្រឹត្តទៅលើពុទ្ធសាសនិក និងមន្ទីរសន្តិសុខក្រាំងតាចាន់។

សវនាការនឹងបើកទូលាយសម្រាប់សាធារណជន និងតំណាងសារព័ត៌មាន ហើយកន្លែងនៅក្នុងសាលសវនាការនឹងត្រូវចែកជូនដោយគោរពតាមគោលការណ៍ អ្នកមកមុន បានមុន។ ច្រកទ្វារចូលសម្រាប់សាធារណជននឹងចាប់ផ្តើមនៅវេលាម៉ោង ៧ ព្រឹក រៀងរាល់ថ្ងៃសវនាការ។ តំណាងប្រព័ន្ធផ្សព្វផ្សាយដែលចូលរួមសវនាការនេះត្រូវយកមកជាមួយនូវប័ណ្ណព័ត៌មានដែលនៅមានសុពលភាពចេញដោយអ.វ.ត.ក។ តំណាងសារព័ត៌មានដែលមិនទាន់មានប័ណ្ណសម្គាល់ខ្លួន ឬអ្នកដែលមានប័ណ្ណហើយ ប៉ុន្តែផុតកំណត់ពេល ត្រូវបំពេញសំណុំបែបបទដើម្បីបានប័ណ្ណនេះនិងដើម្បីចូលរួមក្នុងដំណើរការសវនាការ។ សម្រាប់ទទួលប័ណ្ណសម្គាល់ខ្លួនក្នុងការយកព័ត៌មាន សូមបំពេញទម្រង់បែបបទ ចុះហត្ថលេខា និងសូមភ្ជាប់មកជាមួយនូវរូបថត និងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនថតចម្លង។ ទម្រង់សុំប័ណ្ណសម្គាល់ខ្លួននេះអាចរកបាននៅលើគេហទំព័រអ.វ.ត.ក (http://www.eccc.gov.kh/sites/default/files/ECCC_Accreditation_Media_Application_Form-2014.doc)។

យោងតាមដីកាកំណត់កាលបរិច្ឆេទសវនាការរបស់អង្គជំនុំជម្រះសាលាដំបូង ការចាប់ផ្តើមសវនាការពិនិត្យភស្តុតាងវគ្គដំបូងក្នុងសំណុំរឿង ០០២/០២ នឹងប្រព្រឹត្តទៅចាប់ពីថ្ងៃសុក្រ ទី១៧ ខែតុលា ឆ្នាំ ២០១៤ រហូតដល់ថ្ងៃព្រហស្បតិ៍

ទី១៨ ខែធ្នូ ឆ្នាំ ២០១៤។ អង្គជំនុំជម្រះសាលាដំបូងនឹងដំណើរការសវនាការ៣ ថ្ងៃក្នុង ១ សប្តាហ៍ តាមកាលវិភាគសវនាការប្រចាំថ្ងៃដូចដែលធ្លាប់បានអនុវត្តនៅក្នុងសំណុំរឿង ០០២/០១ ដោយចាប់ ផ្តើមសវនាការពីម៉ោង៩ ព្រឹក និងបញ្ចប់នៅម៉ោង ៤:០០ រសៀល។ សវការនឹងផ្អាកសម្រាប់ការទទួលទានអាហារថ្ងៃត្រង់ពីម៉ោង ១២:០០ ថ្ងៃត្រង់ រហូតដល់ ម៉ោង ១:៣០ រសៀល និងមានការសម្រាកម្តងនៅពេលព្រឹក និងម្តងទៀតនៅពេលរសៀលតាមការណែនាំរបស់ប្រធានអង្គជំនុំជម្រះសាលាដំបូង។

ការផ្សាយបន្តផ្ទាល់ពីដំណើរការសវនាការនេះ នឹងមានជាសំឡេង និងរូបភាព ដែលអាចរកបាននៅលើគេហទំព័ររបស់ អ.វ.ត.ក www.eccc.gov.kh/en/live-stream។

សំណុំរឿង ០០២/០២ គឺជាការជំនុំជម្រះក្តីទី២ ប្រឆាំងនឹង នួន ជា និងខៀវ សំផន។ ទីតាំងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ និងការចោទប្រកាន់តាមអង្គហេតុខាងក្រោមនេះ ជាមូលដ្ឋានសម្រាប់ការជំនុំជម្រះនៃសំណុំរឿង ០០២/០២៖

- បទប្រល័យពូជសាសន៍ចំពោះជនជាតិចាម និងវៀតណាម (ដោយមិនរាប់បញ្ចូលបទឧក្រិដ្ឋ ដែលប្រព្រឹត្តដោយកងទ័ពបដិវត្តន៍កម្ពុជាក្នុងទឹកដីវៀតណាមទេ),
- ការរៀបការដោយបង្ខំ និងបទរំលោភសេពសន្ថវៈ (ទូទាំងប្រទេស),
- ការបោសសម្អាតផ្ទៃក្នុង,
- មន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង មន្ទីរសន្តិសុខភ្នំក្រោល,
- ការដ្ឋានទំនប់ ១ មករា ការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង ការដ្ឋានទំនប់ត្រពាំងថ្ម,
- សហករណ៍ត្រាំកក់,
- ការប្រព្រឹត្តិចំពោះពុទ្ធសាសនិកជន (កម្រិតត្រឹមតែសហករណ៍ត្រាំកក់),
- ការប្រព្រឹត្តិជាក់លាក់លើអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ (ដែលអនុវត្តកម្រិតត្រឹមតែសហករណ៍ត្រាំកក់ ការដ្ឋានទំនប់ ១ មករា មន្ទីរសន្តិសុខ ស-២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់)។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖

**លោក ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទចល័ត: +៨៥៥ (0) ១២ ៤៨៨ ០២៣
សារអេឡិកត្រូនិក: olsenl@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទចល័ត: +៨៥៥ (0) ១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh